ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

រឿង ព្រហ្មទណ្ឌ

លេខ: ១១៦៨

ថ្ងៃ ១២/១២/២០១២

សាលដីកា

លេខ: ០១ ក្រ.IV "ច"

ថ្ងៃ ២៩/០១/២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២៩/០១/២០១៤ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:១១៦៨ ចុះថ្ងៃទី១២/១២/២០១២ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅស្រុកកំពត ខេត្តកំពត។សព្វថ្ងៃផ្ទះលេខ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

***ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត*** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ២៥ ភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩/១១/២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។ បច្ចុប្បន្នៈនៅពន្ធនាគារ ***ស១***

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ នៅផ្ទះលេខ [redacted] ។

***ការប្រព្រឹត្តរបស់ជនជាប់ចោទ***

កាលពីថ្ងៃទី ០៩/១១/២០១០ វេលាម៉ោង ១០ព្រឹក ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង បានទៅផ្ទះរបស់ឈ្មោះ [redacted] ហើយនិយាយសុំខ្ចីម៉ូតូម៉ាកស្កូបពីពណ៌ផ្កាឈូកដែលមានលេខតួ B00២៤៧៩៩ និងលេខម៉ាស៊ីន BE00២៤៧៩៩ ដើម្បីទៅផ្ទះរបស់ខ្លួនមួយភ្លែត។ដោយមានការជឿទុកចិត្តឈ្មោះ [redacted] បានប្រគល់ម៉ូតូរបស់ខ្លួនឲ្យទៅឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង ដើម្បីជិះទៅផ្ទះ។ លុះដល់វេលាម៉ោង ១៧ ថ្ងៃ ខែ ឆ្នាំដដែលឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង បានប្រាប់ [redacted] ថា: ខ្លួនបានយកម៉ូតូទៅដាក់បញ្ចាំបាត់ទៅហើយ ក្រោយមកឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង បានគេចខ្លួនរហូតមកទល់ពេលនេះ ។

៣១៤

*-រឿងនេះសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ០៦ "ខ" ចុះថ្ងៃទី ១៤/០២/២០១២ ដែលមានខ្លឹមសារដូចតទៅ ៖*

១/ផ្តន្ទាទោសឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង ភេទប្រុស អាយុ ២៣ឆ្នាំជាតិខ្មែរដាក់ពន្ធនាគារកំណត់ ១ឆ្នាំ(មួយ) គិតពីថ្ងៃចាប់ខ្លួនបាន និងពិន័យជាប្រាក់ចំនួន១លានរៀល ដាក់ចូលថវិការដ្ឋ។ ពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចផ្ទះលេខ ២៥ ភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩/១១/២០១០ តាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២/បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង សងសំណងរដ្ឋប្បវេណីចំនួន ២.០០០$(ពីរពាន់ដុល្លាអាមេរិក) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។ សុំលើសពីនេះបដិសេធចោល ។

៣/សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៧/០១/២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤/០២/២០១២ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង ប្តឹងទាស់សាលក្រមព្រហ្មទណ្ឌលេខ ០៦ "ខ" ចុះថ្ងៃទី ១៤/០២/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។ (ឯ/២៤ )

*-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦៥ "ខ" ចុះថ្ងៃទី ១៣/៩/២០១២ របស់សាលាដំបូង រាជធានីភ្នំពេញ បានសម្រេចសេចក្តីដែលមានខ្លឹមសារដូចតទៅ ៖*

១/តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ០៦-ខ- ចុះថ្ងៃទី ១៤/០២/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការទាំងមូល ។

-សាលក្រមនេះជំនុំជម្រះថ្ងៃទី ០៦/៩/២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣/៩/២០១២ ចំពោះមុខពិរុទ្ធជន,ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ប្តឹងឧទ្ធរណ៍ និងសាលក្រមព្រហ្មទណ្ឌលេខ ៦៥-ខ- ចុះថ្ងៃទី ១៣/៩/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។(ឯ/៣៥ )

-បានឃើញរបាយការណ៍របស់ចៅក្រមរបាយការណ៍ចុះថ្ងៃទី ០២/៤/២០១៣ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ០៤/៦/២០១៣ ។

## ***នាពេលសវនាការ***

### *ចៅក្រមអានរបាយការណ៍សង្ខេបអង្គហេតុ*

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ នាពេលសវនាការបានឆ្លើយបញ្ជាក់ថាៈខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ការចោទប្រកាន់គឺជារឿងមិនពិត គេឲ្យម៉ូតូ,ឲ្យកាតគ្រីមកខ្ញុំ ព្រោះខ្ញុំនិង [redacted] ជាអ្នករាប់អានគ្នាអស់រយៈពេល ១ខែ ពួកម៉ាក [redacted] ស្គាល់ខ្ញុំ ហើយការរាប់អានគ្នាគឺជាការរាប់អានតៗគ្នា។ នៅថ្ងៃកើតហេតុខ្ញុំមិនបានខ្ចីម៉ូតូគេទេ បើសិនជាខ្ញុំបានប្រព្រឹត្ត គឺខ្ញុំសុខចិត្តទទួលទោស តែរឿងនេះខ្ញុំមិនបានប្រព្រឹត្តទេ ខ្ញុំដើរលេងមិនសូវចូលផ្ទះមែន ខ្ញុំដើរលេងជាមួយពួកម៉ាកស្រីៗ ព្រោះស្រីៗនោះគេជាអ្នកចិញ្ចឹមរូបខ្ញុំ ។ ខ្ញុំមិនធ្លាប់ខ្ចីម៉ូតូគេទេ តែខ្ញុំធ្លាប់បានទៅលួសម៉ូតូចេញពីកន្លែងបញ្ចាំ ។ ម្តាយរបស់ខ្ញុំគាត់បានខឹងខ្ញុំ ព្រោះខ្ញុំដើរលេងមិនសូវចូលផ្ទះ ខ្ញុំមិនដែលដើរលេងជាមួយម្ចាស់ម៉ូតូនេះទេ ខ្ញុំបានស្គាល់គ្នាជិត ១០ខែហើយ តែមិនធ្លាប់បានដើរលេងជាមួយគ្នាទេ ។

***សំណូមពរៈ*** សុំតុលាការមេត្តាលើកលែងទោសដល់រូបខ្ញុំផង ។

## ***សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ***

-ជនជាប់ចោទឈ្មោះ [illegible] សុវណ្ណ នៅពេលសវនាការនេះ មិនព្រមសារភាពពីកំហុសរបស់ខ្លួនទេ តែតាមកំណត់

Scanned with CamScanner

ហេតុយកចម្លើយរបស់ម្តាយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ នៅសាលាដំបូងបានបញ្ជាក់ថា ជនជាប់ចោ[illegible] ចូលចិត្តដើរលេងជាមួយពួកម៉ាក មិនស្តាប់ការណែនាំពីឪពុក-ម្តាយទេ ។

-តំណាងមហាអយ្យការយល់ឃើញថាឈ្មោះ [redacted] សុវណ្ណ នេះជាមនុស្សដែលគ្មានគ្រូបាអាចារ្យណាប្រដៅបានឡើយ ។ គប្បីក្រុមប្រឹក្សាតម្កល់សាលក្រមរបស់តុលាការសាលាដំបូង និងសម្រេចទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី ១៣/៩/២០១២ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៥ "ខ" ចុះថ្ងៃទី ១៣/៩/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយបដិសេធនៅសវនាការឧទ្ធរណ៍ថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ចម្លើយដោះសារនេះ មិនមានមូលដ្ឋានគ្រប់គ្រាន់អាចឲ្យក្រុមប្រឹក្សាជឿបានទេ ពីព្រោះមិនមានលក្ខណៈស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី [redacted] វ៉ាពីន នៅចំពោះមុខអយ្យការ និងនៅចៅក្រមស៊ើបសួរថា : ខ្លួន និងឈ្មោះ [redacted] (វង្ស សុវណ្ណ) ជាមិត្តភ័ក្តរាប់អានគ្នាជាយូរមកហើយ ហើយនៅថ្ងៃកើតហេតុឈ្មោះ [redacted] បានខ្ចីម៉ូតូរបស់ខ្លួន ហើយខ្លួនទុកចិត្តក៏ប្រគល់សោរម៉ូតូឲ្យវា [redacted] សុវណ្ណ)ទៅ ។ ដល់ពេលល្ងាចទើបខ្លួនដឹងថា ឈ្មោះ ឡុង បានយកម៉ូតូរបស់ខ្លួនយកទៅបញ្ចាំបាត់ទៅ (ឯកសារលេខ ២ និង៨) ។

ម្យ៉ាងទៀតតាមការអះអាងរបស់លោកស្រី [redacted] ទ្រព្យ ជាម្តាយរបស់ជនរងគ្រោះ និងលោកស្រី [redacted] យ៉ាង ជាម្តាយរបស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ហៅ ឡុង នៅសវនាការសាលដំបូងថា: ពួកខ្លួនធ្លាប់បានជួបគ្នានៅផ្ទះរបស់ម្តាយជនជាប់ចោទ ដើម្បីសម្រុះសម្រួលរឿងដែលជនជាប់ចោទយកម៉ូតូរបស់ជនរងគ្រោះនោះ អាចឲ្យក្រុមប្រឹក្សាជឿបានថា ឈ្មោះ [redacted] សុវណ្ណ និងឈ្មោះ [redacted] បានរាប់អានគ្នាយូរហើយ រហូតបានស្គាល់អាស័យដ្ឋានរបស់ម្តាយជនជាប់ចោទ ដែលនាំឲ្យឈ្មោះ [redacted] ទុកចិត្តប្រគល់ម៉ូតូឲ្យទៅជនជាប់ចោទខ្ចី ។ នេះក៏ស្របគ្នាទៅនឹងការអះអាងរបស់ជនជាប់ចោទនៅសាលាឧទ្ធរណ៍នេះថា ខ្លួន និងជនរងគ្រោះឈ្មោះ [redacted] ស្គាល់រាប់អានគ្នាជាង១០ខែហើយ មុនពេលខ្លួនខ្ចីម៉ូតូពីឈ្មោះ [redacted] នោះ។ ហេតុនេះក្រុមប្រឹក្សាយល់ឃើញថា មានភស្តុតាង និងសក្ខីកម្មដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ពីបទរំលោភលើទំនុកចិត្ត ស្របតាមមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៣-សាលក្រមព្រហ្មទណ្ឌលេខ ៦៥ "ខ" ចុះថ្ងៃទី១៣/៩/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីសាលាឧទ្ធរណ៍សម្រេចតម្កល់ទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណ ចុះថ្ងៃទី១៣/៩/២០១២ ទុកជាត្រឹមត្រូ[illegible]

៣១៦

Scanned with CamScanner

តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៦៥ "ខ" ចុះថ្ងៃទី ១៣/៩/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធីច្បាប់ ។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៩/០១/២០១៤ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រី ឧទ្ទេសបង្គាប់ អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted] | លោក [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ថ្ងៃទី ០១ ខែ ៥ ឆ្នាំ ២០១៤
ក្រឡាបញ្ជីសវនាការ
[redacted]



Scanned with CamScanner